ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងក្តីរដ្ឋប្បវេណីលេខ១៥៥

**ប.អ.ស/១៩-០៤-២០២២ ។**

**សាលក្រមលេខ២៨ ( ជ )/២៣៧**

**ចុះថ្ងៃទី៣១ខែសីហា ឆ្នាំ២០២២**

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តសៀមរាប

បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅសាលសវនាការលេខ០១ ( ខ ) អគា ( ខ ) ។

កាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃពុធ១២រោច ខែស្រាពណ៍ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនិងថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ វេលាម៉ោងព្រឹក ។

កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃពុធ០៥កើតខែភទ្របទឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនិងថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ វេលាព្រឹក ។

**ចៅក្រមជំនុំជម្រះ**

**លោក** [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប ។

**ក្រឡាបញ្ជី**

**លោក** [redacted]ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប ។

**ដើមចោទ :**

**-ឈ្មោះ** [redacted] **គឹមឡៃ** ភេទស្រី អាយុ៥៣ឆ្នាំ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ១៨០៦៧៤៣៩៨ ចុះថ្ងៃទី១០ខែកុម្ភៈឆ្នាំ២០១៤ មានទីលំនៅបច្ចុប្បន្ននៅ[redacted]។ ដោយមានលោក [redacted]ជាមេធាវីតំណាងដោយអាណត្តិឱ្យ**ដើមចោទឈ្មោះ** [redacted] **គឹមឡៃ** ។

**សហចុងចម្លើយ :**

**១-ឈ្មោះ**[redacted]**ចន្ថា** ភេទស្រីអាយុ៤៧ឆ្នាំ ជនជាតិខ្មែរសញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ[redacted]។

**២-ឈ្មោះ**[redacted]**ដាលី** ភេទស្រីអាយុ៦១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ[redacted]។

**៣-ឈ្មោះ**[redacted]**ដាលី** ភេទស្រីអាយុ៣៧ឆ្នាំជនជាតិខ្មែរសញ្ជាតិខ្មែរមានទីលំនៅបច្ចុប្បន្ននៅ[redacted] ។

Scanned with CamScanner

**កម្មវត្ថុ ៖ ប្តឹងសុំឱ្យតុលាការចេញសាលក្រមសម្រេចដែលមានខ្លឹមសារដូចខាងក្រោម៖**

**១-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ[redacted] ចន្ថា ភេទស្រី.ឈ្មោះ[redacted] ដាលី ភេទស្រីនិងឈ្មោះ[redacted] ដាលី ភេទស្រី សងមកឱ្យដើមចោទឈ្មោះ [redacted] គីមខ្សៃ ភេទស្រី ចំនួន៧៤០០០( ប្រាំពីរម៉ឺនបួនពាន់ )ដុល្លាអាមេរិក.ប្រាក់ពិន័យចំនួន៥៥០០( ប្រាំពាន់ប្រាំរយ ) ដុល្លាអាមេរិកនិងការប្រាក់ចំនួន៥ភាគរយក្នុង០១ឆ្នាំ( ប្រាំភាគរយក្នុងមួយឆ្នាំ )ដោយគិតចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៨រហូតដល់ពេលសងប្រាក់មកឱ្យដើមចោទអស់ ។**

**២-ដើមចោទទាមទារឱ្យសហចុងចម្លើយបង់ជំងឺចិត្តមកឱ្យខ្លួនចំនួន២០០០០(ពីរម៉ឺន )ដុល្លាអាមេរិក ទៅលើចំណាយការខូចខាតពេលវេលា ។**

**៣-ប្រាក់ប្រដាប់ក្តីនិងប្រាក់ពន្ធផ្សេងៗជាបន្ទុករបស់សហចុងចម្លើយ ។**

**៤-ដើមចោទស្នើសុំឱ្យតុលាការប្រកាសអនុវត្តជាបណ្តោះអាសន្នលើចំណុចទី១ នៃការទាមទាររបស់ដើមចោទខាងលើ ។**

**១-អង្គហេតុនិងមូលហេតុនៃការទាមទារ ៖**

-ដើមចោទទាមទារឱ្យសហចុងចម្លើយសងប្រាក់ដើមមកឱ្យខ្លួនចំនួន**៧៤០០០( ប្រាំពីរម៉ឺនបួនពាន់** )ដុល្លាអាមេរិកនិងប្រាក់ពិន័យចំពោះការអនុវត្តកាតព្វកិច្ចយឺតយ៉ាវសរុបចំនួន**៥៥០០( ប្រាំពាន់ប្រាំរយ** )ដុល្លាអាមេរិកដូចមានចែងក្នុងចំណុចទី១ខាងលើ ដោយសារសហចុងចម្លើយ ឈ្មោះ[redacted]ដាលី .ឈ្មោះ[redacted]ចន្ថានិងឈ្មោះ[redacted] ដាលី បានព្រមព្រៀងគ្នាឱ្យឈ្មោះ[redacted] ដាលី ចុះកិច្ចសន្យាខ្ចីប្រាក់ជាលាយលក្ខអក្សរជាមួយដើមចោទហើយឈ្មោះ[redacted]ចន្ថា និងឈ្មោះ[redacted] ដាលី ធ្វើជាអ្នកធានាក្នុងការអនុវត្តកិច្ចសន្យាដោយបានដាក់តម្កល់លិខិតកាន់កាប់ប្រើប្រាស់ដីធ្លី( ប្លង់ដី )មានដំណាក់កាលដូចខាងក្រោម ៖

**-លើកទី១** នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៨ សហចុងចម្លើយបានចុះកិច្ចសន្យាខ្ចីប្រាក់ចំនួន**២៥០០(ពីរពាន់ប្រាំរយ** )ដុល្លាអាមេរិកពីដើមចោទ ។ ក្នុងកិច្ចសន្យាបានកំណត់ពេលសងមកដើមចោទវិញនៅថ្ងៃទី១០ខែឧសភាឆ្នាំ២០១៩ ។ក្នុងករណីសហចុងចម្លើយមិនបំពេញកាតព្វកិច្ចក្នុងកិច្ចសន្យាទេ សហចុងចម្លើយត្រូវបង់ប្រាក់ពិន័យបន្ថែមឱ្យដើមចោទចំនួន៥០០( ប្រាំរយ )ដុល្លាអាមេរិក ។ ក្នុងការខ្ចីប្រាក់ខាងលើសហចុងចម្លើយឈ្មោះ [redacted] ដាលី បានយកប្លង់ដីរបស់ខ្លួនគឺពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១៥១៨/២០១៥ ឃ.តចុះថ្ងៃទី៣០ ខែវិច្ឆិកាឆ្នាំ២០១៥ ។

**-លើកទី២ នៅថ្ងៃទី២៨ខែកញ្ញាឆ្នាំ២០១៨** សហចុងចម្លើយឈ្មោះ [redacted] ដាលី បានមកធ្វើកិច្ចសន្យាដាក់ប្លង់ដីខាងលើដដែលខ្ចីប្រាក់បន្ថែមពីដើមចោទចំនួន**៦០០០( ប្រាំមួយពាន់** )ដុល្លាអាមេរិក ហើយសហចុងចម្លើយសន្យាសងប្រាក់ទៅដើមចោទវិញនៅថ្ងៃទី២៤ខែតុលាឆ្នាំ២០១៩ ។ក្នុងករណីសងទៅដើមចោទមិនទាន់ពេលវេលាតាមកិច្ចសន្យាទេ សហចុងចម្លើយឈ្មោះ [redacted] ដាលី ត្រូវបង់ប្រាក់ពិន័យចំនួន**១០០០( មួយពាន់** )ដុល្លាអាមេរិក ។

**-លើកទី៣ នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩** សហចុងចម្លើយឈ្មោះ [redacted] ដាលី បានមកធ្វើកិច្ចសន្យាដាក់ប្លង់ដីគឺពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ៤៣៨/០១៧ឃ.តចុះថ្ងៃទី២០ខែមីនាឆ្នាំ២០១៧មកដាក់ធានាខ្ចីប្រាក់បន្ថែមពីដើមចោទចំនួន**៦០០០ ( ប្រាំមួយពាន់**)ដុល្លាអាមេរិក ហើយសហចុងចម្លើយសន្យាសងប្រាក់ទៅដើមចោទវិញនៅថ្ងៃទី១៣ ខែមេសាឆ្នាំ២០១៩ ។ ក្នុងករណីសង

Scanned with CamScanner

ទៅដើមចោទមិនទាន់ពេលវេលាតាមកិច្ចសន្យាទេ សហចុងចម្លើយឈ្មោះ [redacted] ដាលី ត្រូវបង់ប្រាក់ពិន័យចំនួន១០០០ ( មួយពាន់ ) ដុល្លាអាមេរិក បន្ថែមទៅឱ្យដើមចោទ។

**-លើកទី៤ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩** សហចុងចម្លើយឈ្មោះ [redacted] ដាលី បានមកធ្វើកិច្ចសន្យាដាក់បួងដីគឺពាក្យស្នើសុំ កាន់កាប់ប្រើប្រាស់ដីធ្លីលេខ០៩០/០៨ឃ.តចុះថ្ងៃទី១៥ខែមករាឆ្នាំ២០០៨ដោយមានការយល់ព្រមពីឈ្មោះ [redacted] កែវ ជាឪពុករបស់ សហចុងចម្លើយឈ្មោះ ចាន់ ដាលីមកដាក់ធានាខ្ចីប្រាក់ បន្ថែមពីដើមចោទចំនួន **៤២០០០ (បួនម៉ឺនពីរពាន់)** ដុល្លាអាមេរិក ហើយសហចុងចម្លើយសន្យាសងប្រាក់ទៅដើមចោទវិញនៅថ្ងៃទី១៥ខែមិថុនា ឆ្នាំ២០១៩ ។ ក្នុងកិច្ចសន្យាខាងលើឈ្មោះសហចុងចម្លើយ ឈ្មោះ [redacted] ដាលី សន្យាថា ក្នុងករណីសងទៅដើមចោទមិនទាន់ពេល វេលាតាមកិច្ចសន្យាទេ សហចុងចម្លើយឈ្មោះ [redacted] ដាលី ត្រូវបង់ប្រាក់ពិន័យចំនួន**២០០០ ( ពីរពាន់ )**ដុល្លាអាមេរិក បន្ថែមទៅឱ្យដើមចោទ។

**-លើកទី៥ នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩** សហចុងចម្លើយឈ្មោះ [redacted] ដាលី បានមកធ្វើកិច្ចសន្យាដាក់បួងដីគឺពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ០៩០/០៨ឃ.តចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៨ ដដែលដោយមានការយល់ព្រមពីឈ្មោះ [redacted] កែវ ជាឪពុករបស់សហចុងចម្លើយឈ្មោះ [redacted] ដាលី មកដាក់ធានាខ្ចីប្រាក់បន្ថែមពីដើមចោទចំនួន **១៦០០០ (មួយម៉ឺនប្រាំមួយពាន់)** ដុល្លាអាមេរិក ហើយសហចុងចម្លើយសន្យាសងប្រាក់ទៅដើមចោទវិញនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ ។ ក្នុងកិច្ចសន្យាខាងលើ សហចុងចម្លើយឈ្មោះ [redacted] ដាលី បានសន្យាថា ក្នុងករណីសងប្រាក់ទៅដើមចោទមិនទាន់ពេលវេលាតាមកិច្ចសន្យាទេ សហចុងចម្លើយឈ្មោះ [redacted] ដាលី ត្រូវបង់ប្រាក់ពិន័យបន្ថែម**ចំនួន១០០០ ( មួយពាន់ )**ដុល្លាអាមេរិក បន្ថែមពីលើប្រាក់ដើមទៅឱ្យដើមចោទ។

**-លើកទី៦ នៅចុងឆ្នាំ២០១៩** សហចុងចម្លើយឈ្មោះ [redacted] ដាលី បានមកធ្វើកិច្ចសន្យាខ្ចីប្រាក់បន្ថែមពីដើមចោទ ដោយមិនបានដាក់ធានាអ្វីទាំងអស់ចំនួន១៥០០( មួយពាន់ប្រាំរយ )ដុល្លាអាមេរិក ដើមចោទយល់ព្រមឱ្យខ្ចីទៀត ហើយសហចុងចម្លើយឈ្មោះ [redacted] ដាលី ថា និងសងប្រាក់មកឱ្យដើមចោទទាំងអស់ក្នុងពេលឆាប់ៗនេះ តែសហចុងចម្លើយឈ្មោះ [redacted] ដាលី មិនបានគោរពតាមកិច្ចសន្យានីមួយៗខាងលើនឹងមិនបានសងប្រាក់មកដើមចោទទៅថែមទាំងបានរត់គេចខ្លួនទៀត ។ នៅក្នុងកិច្ចសន្យាខ្ចីប្រាក់ទាំង០៦លើក ខាងលើ សហចុងចម្លើយឈ្មោះ [redacted] ដាលី ម្នាក់ឯងជាអ្នកយកប្រាក់ពីដើមចោទផ្ទាល់ដៃ រីឯចំពោះសហចុងចម្លើយឈ្មោះ [redacted] ដាលី និងឈ្មោះ [redacted] ចន្ថា គ្រាន់តែជាអ្នកនាំមកខ្ចីនិងជាអ្នកដឹងឮធ្វើជាសាក្សីនិងផ្តិតមេដៃលើកិច្ចសន្យាខ្ចីប្រាក់រវាងដើមចោទនិងសហចុងចម្លើយឈ្មោះ [redacted] ដាលី តែប៉ុណ្ណោះ ។ ចំពោះការទាមទាររបស់ដើមចោទខាងលើ គឺសំអាងទៅលើកិច្ចសន្យាចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៨ របស់សហចុងចម្លើយឈ្មោះ [redacted] ដាលី ជាមួយដើមចោទឈ្មោះ [redacted] គឹមឡៃ ។

**នាពេលទាញហេតុផលដោយផ្ទាល់មាត់**

**-ដើមចោទឈ្មោះ [redacted] គឹមឡៃ ដោយមានលោក [redacted] សាមឌី ជាមេធាវីតំណាងដោយអាណត្តិ បានធ្វើសេចក្តីថ្លែងការណ៍និងអះអាងទាមទារថា :**

១-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ចន្ថា ភេទស្រី.ឈ្មោះ [redacted] ដាលី ភេទស្រីនិងឈ្មោះ [redacted] ដាលី ភេទស្រី សងប្រាក់ដើមមកឱ្យដើមចោទឈ្មោះ [redacted] គឹមឡៃ ភេទស្រី ចំនួន៧៤០០០( ប្រាំពីរម៉ឺនបួនពាន់ )ដុល្លាអាមេរិក.ប្រាក់ពិន័យ ចំនួន៥៥០០

( ប្រាំពាន់ប្រាំរយ ) ដុល្លារអាមេរិកនិងការប្រាក់ចំនួន៥ភាគរយក្នុង០១ឆ្នាំ( ប្រាំភាគរយក្នុងមួយឆ្នាំ ) ដោយគិតចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៨ រហូតដល់ពេលសងប្រាក់មកឱ្យដើមចោទអស់ ។

**២-ដើមចោទទាមទារឱ្យសហចុងចម្លើយបង់ជំងឺចិត្តមកឱ្យខ្លួនចំនួន២០០០០( ពីរម៉ឺន )ដុល្លារអាមេរិក ទៅលើចំណាយការខូចខាតពេលវេលា ។**

**៣-ប្រាក់ប្រដាប់ក្តីនិងប្រាក់ពន្ធផ្សេងៗជាបន្ទុករបស់សហចុងចម្លើយ ។**

**៤-ដើមចោទស្នើសុំឱ្យតុលាការប្រកាសអនុវត្តជាបណ្តោះអាសន្នលើចំណុចទី១ នៃការទាមទាររបស់ដើមចោទខាងលើ ។ដោយហេតុថា** ខ្លួនជាដើមចោទនៅតែទាមទារឱ្យសហចុងចម្លើយសងប្រាក់ដើមមកឱ្យខ្លួនចំនួន**៧៤០០០( ប្រាំពីរម៉ឺនបួនពាន់** )ដុល្លារអាមេរិកនិងប្រាក់ពិន័យ ចំពោះការអនុវត្តកាតព្វកិច្ចយឺតយ៉ាវសរុបចំនួន**៥៥០០( ប្រាំពាន់ប្រាំរយ** ) ដុល្លារអាមេរិក ដូចមានចែងក្នុងចំណុចទី១ ខាងលើដោយសារសហចុងចម្លើយ ឈ្មោះ[redacted] ដាលី .ឈ្មោះ[redacted] ចន្ថានិងឈ្មោះ[redacted] ដាលី បានព្រមព្រៀងគ្នាឱ្យឈ្មោះ[redacted] ដាលី ចុះកិច្ចសន្យាខ្ចីប្រាក់ជាលាយលក្ខអក្សរជាមួយដើមចោទហើយឈ្មោះ[redacted] ចន្ថា និងឈ្មោះ[redacted] ដាលី ធ្វើជាអ្នកធានាក្នុងការអនុវត្តកិច្ចសន្យាដោយ បានដាក់កម្មសិទ្ធិលិខិតកាន់កាប់ប្រើប្រាស់ដីធ្លី( ប្លង់ដី ) មានដំណាក់កាលដូចខាងក្រោម :

**-លើកទី១** នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៨ សហចុងចម្លើយបានចុះកិច្ចសន្យាខ្ចីប្រាក់ចំនួន**២៥០០( ពីរពាន់ប្រាំរយ** )ដុល្លារអាមេរិកពីដើមចោទ ។ ក្នុងកិច្ចសន្យាបានកំណត់ពេលសងមកដើមចោទវិញនៅថ្ងៃទី១០ខែឧសភាឆ្នាំ២០១៩ ។ក្នុងករណីសហចុងចម្លើយមិនបំពេញកាតព្វកិច្ចក្នុងកិច្ចសន្យាទេ សហចុងចម្លើយត្រូវបង់ប្រាក់ពិន័យបន្ថែមឱ្យដើមចោទចំនួន៥០០( ប្រាំរយ )ដុល្លារអាមេរិក ។ ក្នុងការខ្ចីប្រាក់ខាងលើសហចុងចម្លើយឈ្មោះ[redacted] ដាលី បានយកប្លង់ដីរបស់ខ្លួនគឺពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១៥១៨/២០១៥ ឃ.ត ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ ។

**-លើកទី២ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨** សហចុងចម្លើយឈ្មោះ[redacted] ដាលី បានមកធ្វើកិច្ចសន្យាដាក់ប្លង់ដីខាងលើដដែលខ្ចីប្រាក់បន្ថែមពីដើមចោទចំនួន**៦០០០( ប្រាំមួយពាន់** )ដុល្លារអាមេរិក ហើយសហចុងចម្លើយសន្យាសងប្រាក់ទៅដើមចោទវិញនៅថ្ងៃទី២៤ ខែតុលាឆ្នាំ២០១៩ ។ក្នុងករណីសងទៅដើមចោទមិនទាន់ពេលវេលាតាមកិច្ចសន្យាទេ សហចុងចម្លើយឈ្មោះ [redacted] ដាលី ត្រូវបង់ប្រាក់ពិន័យចំនួន**១០០០( មួយពាន់** )ដុល្លារអាមេរិក ។

**-លើកទី៣ នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩** សហចុងចម្លើយឈ្មោះ [redacted] ដាលី បានមកធ្វើកិច្ចសន្យាដាក់ប្លង់ដីគឺពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ៤៣៨/០១៧ឃ.តចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ មកដាក់ធានាខ្ចីប្រាក់បន្ថែមពីដើមចោទចំនួន **៦០០០ ( ប្រាំមួយពាន់**)ដុល្លារអាមេរិក ហើយសហចុងចម្លើយសន្យាសងប្រាក់ទៅដើមចោទវិញនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៩ ។ ក្នុងករណីសងទៅដើមចោទមិនទាន់ពេលវេលាតាមកិច្ចសន្យាទេ សហចុងចម្លើយឈ្មោះ [redacted] ដាលី ត្រូវបង់ប្រាក់ពិន័យចំនួន១០០០ ( មួយពាន់ )ដុល្លារអាមេរិក បន្ថែមទៅឱ្យដើមចោទ ។

**-លើកទី៤ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩** សហចុងចម្លើយឈ្មោះ[redacted] ដាលី បានមកធ្វើកិច្ចសន្យាដាក់ប្លង់ដីគឺពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ០៥០/០៨ឃ.តចុះថ្ងៃទី១៥ខែមករាឆ្នាំ២០០៨ដោយមានការយល់ព្រមពីឈ្មោះ[redacted] កែវ ជាឪពុករបស់សហចុងចម្លើយឈ្មោះ [redacted] ដាលីមកដាក់ធានាខ្ចីប្រាក់បន្ថែមពីដើមចោទចំនួន **៤២០០០ ( បួនម៉ឺនពីរពាន់)** ដុល្លារអាមេរិក ហើយសហចុងចម្លើយសន្យាសងប្រាក់ទៅដើមចោទវិញនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៩ ។ ក្នុងកិច្ចសន្យាខាងលើសហចុងចម្លើយ ឈ្មោះ[redacted]

Scanned with CamScanner

ដាលី សន្យាថា ក្នុងករណីសងប្រាក់ទៅដើមចោទមិនទាន់ពេលវេលាតាមកិច្ចសន្យាទេ សហចុងចម្លើយឈ្មោះ [redacted] ដាលី ត្រូវបង់ប្រាក់ពិន័យចំនួន២០០០ ( **ពីរពាន់** )ដុល្លារអាមេរិក បន្ថែមទៀតទៅឱ្យដើមចោទ។

**-លើកទី៥ នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩** សហចុងចម្លើយឈ្មោះ [redacted] ដាលី បានមកធ្វើកិច្ចសន្យាដាក់ប្លង់ដីពីពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ០៤០/០៨ឃ.ត ចុះថ្ងៃទី១៥ខែមករាឆ្នាំ២០០៨ ដដែលដោយមានការយល់ព្រមពីឈ្មោះ [redacted] កែវ ជាឪពុករបស់សហចុងចម្លើយឈ្មោះ [redacted] ដាលី មកដាក់ធានាខ្ចីប្រាក់បន្ថែមពីដើមចោទចំនួន **១៦០០០ (មួយម៉ឺនប្រាំមួយពាន់)** ដុល្លារអាមេរិក ហើយសហចុងចម្លើយសន្យាសងប្រាក់ទៅដើមចោទវិញនៅថ្ងៃទី០៤ខែតុលាឆ្នាំ២០១៩។ក្នុងកិច្ចសន្យាខាងលើ សហចុងចម្លើយឈ្មោះ [redacted] ដាលី សន្យាថា ក្នុងករណីសងប្រាក់ទៅដើមចោទមិនទាន់ពេលវេលាតាមកិច្ចសន្យាទេ សហចុងចម្លើយ ឈ្មោះ [redacted] ដាលី ត្រូវបង់ប្រាក់ពិន័យ**ចំនួន១០០០ ( មួយពាន់** )ដុល្លារអាមេរិក បន្ថែមទៀតទៅឱ្យដើមចោទ។

**-លើកទី៦ នៅចុងឆ្នាំ២០១៩** សហចុងចម្លើយឈ្មោះ [redacted] ដាលី បានមកធ្វើកិច្ចសន្យាខ្ចីប្រាក់បន្ថែមពីដើមចោទ ដោយមិនបានដាក់ធានាអ្វីទាំងអស់ចំនួន១៥០០( មួយពាន់ប្រាំរយ )ដុល្លារអាមេរិកដើមចោទយល់ព្រមឱ្យខ្ចីទៀត ហើយសហចុងចម្លើយឈ្មោះ [redacted] ដាលី ថា នឹងសងប្រាក់មកឱ្យដើមចោទទាំងអស់ក្នុងពេលឆាប់ៗនេះ តែសហចុងចម្លើយឈ្មោះ [redacted] ដាលី មិនបានគោរពតាមកិច្ចសន្យាទីមួយៗខាងលើនិងមិនបានសងប្រាក់មកដើមចោទទេ ថែមទាំងបានរត់គេចខ្លួនទៀត ។ នៅក្នុងកិច្ចសន្យាខ្ចីប្រាក់ទាំង០៦លើក ខាងលើសហចុងចម្លើយឈ្មោះ [redacted] ដាលី ម្នាក់ឯងជាអ្នកយកប្រាក់ពីដើមចោទដោយផ្ទាល់ដៃ រីឯចំពោះសហចុងចម្លើយឈ្មោះ [redacted] ដាលី និងឈ្មោះ [redacted] ចន្ថា គ្រាន់តែជាអ្នកនាំមកខ្ចីនិងជាអ្នកដឹងឮធ្វើជាសាក្សីនិងផ្តិតមេដៃលើកិច្ចសន្យាខ្ចីប្រាក់រវាងខ្លួនជាដើមចោទនិងសហ ចុងចម្លើយឈ្មោះ [redacted] ដាលី តែប៉ុណ្ណោះ ។នៅពេលនេះដែរខ្លួនជាដើមចោទស្នើសុំឱ្យតុលាការសម្រេច ដោយបង្គាប់ឱ្យសហចុងចម្លើយ ឈ្មោះ [redacted] ដាលី តែម្នាក់ឯងសងប្រាក់មកឱ្យខ្លួនគ្រប់ចំនួនដូចការទាមទាររបស់ខ្លួននៅក្នុងពាក្យបណ្តឹងខាងលើមកឱ្យខ្លួនជាដើមចោទ។

**-សហចុងចម្លើយ ឈ្មោះ [redacted] ចន្ថា បានធ្វើសេចក្តីថ្លែងការណ៍និង អះអាងថា** កាលនៅដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ខ្លួនទទួលស្គាល់ការទាមទារគ្រប់ចំណុចទាំងអស់របស់ដើមចោទ តែនៅពេលនេះខ្លួនសុំបដិសេធចោលការទាមទាររបស់ដើមចោទមកលើខ្លួនម្នាក់ឯងតែខ្លួននៅតែទទួលស្គាល់ការទាមទារ របស់ដើមចោទគ្រប់ចំណុចនៃពាក្យបណ្តឹងខាងលើរបស់ដើមចោទទៅលើសហចុងចម្លើយឈ្មោះ [redacted] ដាលី ពិតជាជាត្រឹមត្រូវតាមផ្លូវច្បាប់ ដោយសំអាងហេតុថា ខ្លួនជាមួយ សហចុងចម្លើយឈ្មោះ [redacted] ដាលី ស្គាល់ដើមចោទមុន ក្រោយមកបានស្គាល់សហចុងចម្លើយឈ្មោះ [redacted] ដាលី ហើយឈ្មោះ [redacted] ដាលី មិនដែលស្គាល់ដើមចោទទេ តែឈ្មោះចាន់ ដាលីបានដើររកខ្ចីលុយចងការប្រាក់ហើយបានមកជួបខ្លួន។ បន្ទាប់មក [redacted] ដាលី បាន នាំខ្លួនជាមួយ ឈ្មោះ [redacted] ដាលី ទៅមើលដីរបស់គាត់នៅស្រុកបន្ទាយស្រីពេលទៅដល់កន្លែងដីហើយខ្លួនជាមួយ [redacted] ដាលី សួរអ្នកជិតខាងព្រំដីទាំង០៣ប្លង់និងសួរអាជ្ញាធរភូមិឃុំគាត់បានបញ្ជាក់ថាពិតជាដីរបស់ឈ្មោះ [redacted] ដាលីនិងឪពុករបស់គាត់ឈ្មោះ [redacted] កែវ ពិតប្រាកដមែន។ ក្រោយពីសួរនាំនិង ពិនិត្យមើលទីតាំងដីរបស់ឈ្មោះ [redacted] ដាលី រួចបាននាំឈ្មោះចាន់ ដាលីទៅជួបដើមចោទ ហើយដើមចោទបានពិនិត្យប្លង់ដីទាំង០៣ប្លង់រួចបានធ្វើកិច្ចសន្យាខ្ចីប្រាក់និងបានព្រមព្រៀងការប្រាក់និងប្រាក់ពិន័យគ្រប់ដំណាក់កាលខ្ចីទាំងអស់ដោយឈ្មោះ [redacted] ដាលី មិនប្រកែកទេ ហើយដើមចោទមិនបានបង្ខំដែរ ។ក្នុងគ្រប់ដំណាក់កាលខ្ចីទាំងអស់លុយឈ្មោះចាន់ ដាលី ទទួលយកពីដើមចោទតែម្នាក់ឯងខ្លួនជាមួយឈ្មោះ [redacted] ដាលី គ្រាន់តែជាអ្នកដឹងឮនិងធ្វើជាសាក្សីតែប៉ុណ្ណោះ និងបានលុយទឹកតែពីឈ្មោះ [redacted]

Scanned with CamScanner

ដាលី តែបន្តិចបន្តួច តែប៉ុណ្ណោះ ។ក្នុងការខ្ចីប្រាក់ម្តងៗឈ្មោះចាន់ ដាលីឱ្យពួកខ្លួនក្នុងម្នាក់ចំនួន១០០ទៅ២០០ដុល្លារអាមេរិកប៉ុណ្ណោះ ហេតុផលទាំងនេះហើយ ទើបនៅពេលនេះខ្លួនសុំបដិសេធការប្តឹងទាមទាររបស់ដើមចោទគ្រប់ចំណុចនៃពាក្យបណ្តឹងខាងលើ មកលើខ្លួន តែនៅពេលនេះដែរខ្លួនស្នើសុំឱ្យតុលាការសម្រេច ឱ្យសហចុងចម្លើយឈ្មោះ [redacted] ដាលី ម្នាក់ឯងសងប្រាក់ដែលជំពាក់ដើម ចោទទៅដើមចោទតាមការប្តឹងទាមទាររបស់ដើមចោទនិងស្នើសុំឱ្យ តុលាការរឹបអូសដីទំហំប្រហែលជាជាង០៤ហិកតា ដែលឈ្មោះ [redacted] ដាលី បានដាក់ប្លង់ដីដិកល់ទៅដើមចោទក្នុងការខ្ចីលុយពីដើមចោទដើម្បីលក់ឡាយឡុងយកប្រាក់សងទៅដើមចោទ ។

**-សហចុងចម្លើយឈ្មោះ [redacted] ដាលី បានធ្វើសេចក្តីថ្លែងការណ៍និងធ្វើការអះអាងថា** កាលនៅដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ខ្លួនទទួលស្គាល់ការទាមទារគ្រប់ចំណុចទាំងអស់របស់ដើមចោទ តែនៅពេលនេះខ្លួនសុំបដិសេធចោលការទាមទាររបស់ដើមចោទគ្រប់ចំណុចនៃពាក្យបណ្តឹងខាងលើរបស់ដើមចោទមកលើខ្លួនម្នាក់ឯង តែខ្លួននៅតែទទួលស្គាល់ការទាមទាររបស់ដើមចោទគ្រប់ចំណុចនៃពាក្យរបស់ខាងលើរបស់ដើមចោទទៅលើសហចុងចម្លើយឈ្មោះ [redacted] ដាលី ហើយការទាមទារនេះពិតជាត្រឹមត្រូវតាមផ្លូវច្បាប់ ដោយសំអាងហេតុថា ខ្លួនជាមួយសហចុងចម្លើយ ឈ្មោះ [redacted] ចន្ថា ស្គាល់ដើមចោទមុន ក្រោយមកបានស្គាល់សហចុងចម្លើយ ឈ្មោះ [redacted] ដាលី ហើយឈ្មោះ [redacted] ដាលី មិនដែលស្គាល់ដើមចោទទេ តែឈ្មោះ [redacted] ដាលីដើររកខ្ចីលុយចងការប្រាក់ ហើយបានមកជួបខ្លួន។បន្ទាប់មកឈ្មោះ [redacted] ដាលី បាននាំខ្លួនជាមួយឈ្មោះ [redacted] ចន្ថា ទៅមើលដីរបស់គាត់ នៅស្រុកបន្ទាយស្រី ។ពេលពួកខ្លួនទៅដីហើយខ្លួនជាមួយ ឈ្មោះ [redacted] ចន្ថា សួរអ្នកជិតខាងព្រំដីទាំង០៣ ប្លង់និងសួរអាជ្ញាធរភូមិឃុំពួកគាត់បានប្រាប់បញ្ជាក់ថាពិតជាដីរបស់សហចុងចម្លើយឈ្មោះ [redacted] ដាលី និងឪពុកបង្កើតរបស់គាត់ឈ្មោះ [redacted] កែវ មែន ។ក្រោយពីសួរនាំនិងពិនិត្យមើលទីតាំងរបស់ឈ្មោះ [redacted] ដាលី រួចពួកខ្លួនបាននាំឈ្មោះចាន់ ដាលី ទៅជួបដើមចោទ ហើយដើមចោទបានពិនិត្យប្លង់ដីទាំង០៣ប្លង់រួច បានធ្វើកិច្ចសន្យាខ្ចីប្រាក់និងបានព្រមព្រៀងការប្រាក់និងប្រាក់ ពិន័យគ្រប់ដំណាក់កាលខ្ចីទាំងអស់ដោយ ឈ្មោះ [redacted] ដាលី មិនប្រកែកទេ ហើយដើមចោទមិនបានបង្ខំដែរ ។ ក្នុងគ្រប់ដំណាក់កាលខ្ចីប្រាក់ទាំងអស់លុយឈ្មោះ [redacted] ដាលី ទទួលយកពីដើមចោទតែម្នាក់ឯង ខ្លួនជាមួយឈ្មោះ [redacted] ចន្ថាគ្រាន់តែជាអ្នកដឹងឮនិងជាសាក្សី តែប៉ុណ្ណោះនិងបានលុយទឹកតែ ពីឈ្មោះ [redacted] ដាលី តែបន្តិចបន្តួចតែប៉ុណ្ណោះក្នុងការខ្ចីម្តងៗឈ្មោះចាន់ ដាលីឱ្យពួកខ្លួនក្នុងម្នាក់ចំនួន១០០ ទៅ២០០ ដុល្លារអាមេរិក ប៉ុណ្ណោះ ហេតុផលទាំងអស់នេះហើយ ទើបខ្លួនបដិសេធការប្តឹងទាមទាររបស់ដើមចោទគ្រប់ចំណុចនៃពាក្យបណ្តឹង ខាងលើមកលើខ្លួន តែនៅពេលនេះខ្លួនស្នើសុំឱ្យតុលាការសម្រេច ឱ្យសហចុងចម្លើយឈ្មោះ [redacted] ដាលី តែម្នាក់ឯងសងប្រាក់ដែលជំពាក់ដើមទៅដើមចោទតាមការប្តឹងទាមទាររបស់ដើមចោទ និងស្នើសុំឱ្យតុលាការរឹបអូសដីទំហំប្រហែលជាជាង០៤ហិកតាដែលសហចុងចម្លើយឈ្មោះ [redacted] ដាលី ដាក់ដិកល់ទៅដើមចោទក្នុងការខ្ចីលុយពីដើមចោទលក់ឡាយឡុងយកប្រាក់សងដើមចោទ ។

**-សហចុងចម្លើយឈ្មោះ [redacted] ដាលី មិនបានចូលខ្លួនមកតុលាការតាមកាលកំណត់របស់តុលាការទេ ដោយហេតុថាសហចុងចម្លើយឈ្មោះ [redacted] ដាលី បានរត់គេចខ្លួនមិនដឹងទៅទីណាទេ ចាប់តាំងពីដើមចោទបានដាក់ពាក្យបណ្តឹងរហូតដល់ដីកាកោះពីតុលាការ ទូវដំណាក់កាលនីតិវិធីត្រៀមរហូតដល់ដំណាក់ទាញហេតុផលដោយផ្ទាល់មាត់ ក៏សហចុងចម្លើយឈ្មោះ [redacted] ដាលី មិនបានចូលខ្លួនហើយមិនបានទទួលដីកាកោះពីតុលាការគ្រប់ដំណាក់កាលទាំងអស់ ទោះបីតុលាការបានយកដីកាកោះទៅបិទនៅតាមមូលដ្ឋានរបស់គាត់ក៏ដោយ ។**

**-ចំណុចវិវាទនិងចំណុចគ្មានវិវាទ :**

**-ចំណុចមានវិវាទគឺមាន : គ្រប់ចំណុចនៃការទាមទាររបស់ដើមចោទទាំងអស់ ។**

**-ចំណុចគ្មានវិវាទគឺ : គ្មាន ។**

**៣-ការពិនិត្យភស្តុតាង**

**-ភស្តុតាងរបស់ដើមចោទមាន :**

**១**-កិច្ចសន្យាកិច្ចប្រាក់ចំនួន២៥០០(ពីរពាន់ប្រាំរយ )ដុល្លាអាមេរិក ចុះថ្ងៃទី០១ខែឧសភាឆ្នាំ២០១៨ និងពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១៥១៨/២០១៥ឃ.ត ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ ចេញដោយមេឃុំត្បែង (ថតចម្លង ចំនួន០២ច្បាប់ ) ។

**២**-កិច្ចសន្យាខ្ចីប្រាក់ចំនួន៦០០០(ប្រាំមួយពាន់ )ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ និងពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១៥១៨/២០១៥ ឃ.ត ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ ចេញដោយមេឃុំត្បែង (ថតចម្លង ចំនួន០២ច្បាប់ ) ។

**៣**-កិច្ចសន្យាខ្ចីប្រាក់ចំនួន៦០០០(ប្រាំមួយពាន់ )ដុល្លាអាមេរិក ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ និងលិខិតស្នើសុំកាន់កាប់ដីធ្លីលេខ៤៣៨/០១៧ឃ.ត ចុះថ្ងៃទី២០ ខែមីនាឆ្នាំ២០១៧ ចេញដោយមេឃុំត្បែង (ថតចម្លង ចំនួន០២ច្បាប់ ) ។

**៤**-កិច្ចសន្យាកិច្ចប្រាក់ចំនួន៤២០០០(បួនម៉ឺនពីរពាន់ )ដុល្លាអាមេរិក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ និងពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ០៩០/០៨ ឃ.ត ចុះថ្ងៃទី១៥ខែមករាឆ្នាំ២០០៨ ចេញដោយមេឃុំត្បែង ចំនួន០១ច្បាប់(ថតចម្លង ចំនួន០២ច្បាប់ ) ។

**៥**-កិច្ចសន្យាកិច្ចប្រាក់ចំនួន១៦០០០(មួយម៉ឺនប្រាំមួយពាន់ )ដុល្លាអាមេរិក ចុះថ្ងៃទី០៤ខែសីហាឆ្នាំ២០១៩និងពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ០៩០/០៨ឃ.តចុះថ្ងៃទី១៥ខែមករាឆ្នាំ២០០៨ចេញដោយមេឃុំត្បែងចំនួន០១ច្បាប់(ថតចម្លងចំនួន០២ច្បាប់ ) ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះម៉ិល គីមឡៃ (ថតចម្លងចំនួន០១ច្បាប់ ) ។

**២-ភស្តុតាងរបស់សហចុងចម្លើយ មាន :**

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ[redacted]ដាលី (ថតចម្លងចំនួន០១ច្បាប់ ) ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ[redacted] ចន្ថា (ថតចម្លងចំនួន០១ច្បាប់ ) ។

## សំអាងហេតុ

១-តាមពាក្យបណ្តឹងអង្គសេចក្តីលេខ១៥៥ ប.អ.ស ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ របស់ដើមចោទឈ្មោះ[redacted] គីមឡៃ ដោយ មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ តុលាការអាចលើកយកមកទាញហេតុផលដោយផ្ទាល់មាត់បានតាមបញ្ញត្តិមាត្រា១០និងមាត្រា២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-តាមសេចក្តីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] គីមឡៃ ដោយមានលោក[redacted]ជាមេធាវីតំណាងដោយអាណត្តិ.ការអះអាងរបស់សហចុងចម្លើយនៅក្នុងនីតិវិធីត្រៀមនិងក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់.តាមមាត្រា៤០៧មាត្រា ៤០៨ មាត្រា៤០៩នៃក្រមរដ្ឋប្បវេណីនិងការពិនិត្យភស្តុតាងជាឯកសារ ដែលមាននៅក្នុងសំណុំរឿងខាងលើបានបញ្ជាក់ឱ្យឃើញថា :

Scanned with CamScanner

**-ការទាមទាររបស់ដើមចោទក្នុងចំណុចទី១**

-ដើមចោទឈ្មោះ [redacted] គីមឡៃ និងសហចុងចម្លើយឈ្មោះ [redacted] ដាលី បានព្រមព្រៀងគ្នាធ្វើកិច្ចសន្យាខ្ចីចងការប្រាក់ដោយ មានសហចុងចម្លើយឈ្មោះ [redacted] ដាលី ភេទស្រីនិងសហចុងចម្លើយឈ្មោះ [redacted] ចន្ទាភេទស្រីបានចូលរួមផ្តិតមេដៃលើកិច្ចសន្យាខ្ចីចងការប្រាក់ធ្វើជាសាក្សីដឹង ឮថាសហចុងចម្លើយឈ្មោះ [redacted] ដាលី ពិតជាបានធ្វើកិច្ចសន្យាខ្ចីចងការប្រាក់ពីដើមចោទឈ្មោះ [redacted] គីមឡៃ ពិតប្រាកដមែន ដោយសហចុងចម្លើយឈ្មោះ [redacted] ដាលី ខ្ចីចងការប្រាក់ពីដើមចោទជាបន្តបន្ទាប់មានចំនួន០៦លើកមានដូចជា :

**១-លើកទី១** នៅថ្ងៃទី០១ខែឧសភាឆ្នាំ២០១៨សហចុងចម្លើយឈ្មោះ [redacted] ដាលីបានចុះកិច្ចសន្យាខ្ចីចងការ ពីដើមចោទប្រាក់ចំនួន **២៥០០(ពីរពាន់ប្រាំរយ** )ដុល្លារអាមេរិក ។ ក្នុងកិច្ចសន្យាខ្ចីបានកំណត់ពេលសងប្រាក់មកដើមចោទវិញនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ។ក្នុងករណីសហចុងចម្លើយមិន បំពេញកាតព្វកិច្ចក្នុងកិច្ចសន្យាទេសហចុងចម្លើយត្រូវបង់ប្រាក់ពិន័យបន្ថែមមកឱ្យដើមចោទចំនួន៥០០( ប្រាំរយ )ដុល្លារអាមេរិក ។ ក្នុងការខ្ចីប្រាក់ខាងលើសហចុងចម្លើយឈ្មោះ [redacted] ដាលី បានយកប្លង់ដីរបស់ខ្លួនគឺពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១៥១៨/ ២០១៥ ឃ.តចុះថ្ងៃទី៣០ ខែវិច្ឆិកាឆ្នាំ២០១៥ ។

**២-លើកទី២ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨** សហចុងចម្លើយឈ្មោះ [redacted] ដាលី បានមកធ្វើកិច្ចសន្យាខ្ចីចងការប្រាក់ពីដើមចោទបានដាក់ប្លង់ដីខាងលើដដែលខ្ចីប្រាក់ បន្ថែមពីដើមចោទចំនួន**៦០០០( ប្រាំមួយពាន់** )ដុល្លារអាមេរិក ហើយសហចុងចម្លើយសន្យាសងប្រាក់ទៅ ដើមចោទវិញនៅថ្ងៃទី២៤ ខែតុលាឆ្នាំ២០១៩ ។ក្នុងករណីសងទៅដើមចោទមិនទាន់ពេលវេលាតាមកិច្ចសន្យាទេ សហចុងចម្លើយឈ្មោះ [redacted] ដាលី ត្រូវបង់ប្រាក់ពិន័យចំនួន**១០០០( មួយពាន់** )ដុល្លារអាមេរិក បន្ថែមមកឱ្យដើមចោទ។

**៣-លើកទី៣ នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩** សហចុងចម្លើយឈ្មោះ [redacted] ដាលី បានមកធ្វើកិច្ចសន្យាខ្ចីចងការប្រាក់ពីដើមចោទទៀតនិងបានដាក់ប្លង់ដីគឺពាក្យស្នើសុំកាន់ កាប់ប្រើប្រាស់ដីធ្លីលេខ៤៣៨/០១៧ឃ.តចុះថ្ងៃទី២០ខែមីនាឆ្នាំ២០១៧ មកដាក់ធានាខ្ចីប្រាក់បន្ថែមពីដើមចោទចំនួន**៦០០០ ( ប្រាំ មួយពាន់**)ដុល្លារអាមេរិក ហើយសហចុងចម្លើយឈ្មោះ [redacted] ដាលីបានសន្យាសងប្រាក់ទៅដើមចោទវិញនៅថ្ងៃទី១៣ខែមេសាឆ្នាំ២០១៩ ។ ក្នុងករណីសងប្រាក់ទៅដើមចោទមិនទាន់ពេលវេលាតាមកិច្ចសន្យាទេ សហចុងចម្លើយ ឈ្មោះ [redacted] ដាលី ត្រូវបង់ប្រាក់ពិន័យចំនួន១០០០ ( មួយពាន់ ) ដុល្លារអាមេរិក បន្ថែមទៅឱ្យដើមចោទ។

**៤-លើកទី៤ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩** សហចុងចម្លើយឈ្មោះ [redacted] ដាលី បានមកធ្វើកិច្ចសន្យាខ្ចីចងការប្រាក់ពីដើមចោទទៀតបានដាក់ប្លង់ដីគឺពាក្យស្នើសុំកាន់ កាប់ប្រើប្រាស់ដីធ្លីលេខ០៩០/០៨ឃ.តចុះថ្ងៃទី១៥ខែមករាឆ្នាំ២០០៨ ដោយមានការយល់ព្រមពីឈ្មោះ [redacted] កែវ ជាឪពុកបង្កើតរបស់សហចុងចម្លើយឈ្មោះ [redacted] ដាលី មកដាក់ធានាខ្ចីប្រាក់បន្ថែមពីដើមចោទចំនួន **៤២០០០ (បួនម៉ឺនពីរពាន់)** ដុល្លារអាមេរិក ហើយសហចុងចម្លើយសន្យាសងប្រាក់ទៅដើមចោទវិញនៅថ្ងៃទី១៥ខែមិថុនា ឆ្នាំ២០១៩ ។ ក្នុងកិច្ចសន្យាខាងលើឈ្មោះសហចុងចម្លើយឈ្មោះ [redacted] ដាលី សន្យា ថា ក្នុង ករណីសងទៅដើមចោទមិនទាន់ពេលវេលាតាមកិច្ចសន្យាទេ សហចុងចម្លើយឈ្មោះ [redacted] ដាលី ត្រូវបង់ប្រាក់ពិន័យចំនួន**២០០០ (ពីរពាន់** )ដុល្លារអាមេរិក បន្ថែមទៅឱ្យដើមចោទ។

**៥-លើកទី៥ នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩** សហចុងចម្លើយឈ្មោះ [redacted] ដាលី បានមកធ្វើកិច្ចសន្យាដាក់ប្លង់ដីគឺពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ០៩០/០៨ឃ.តចុះថ្ងៃទី១៥ខែមករាឆ្នាំ២០០៨ដដែលដោយមានការយល់ព្រមពីឈ្មោះចាន់ [redacted] ជាឪពុករបស់សហចុងចម្លើយឈ្មោះ [redacted] ដាលីមកដាក់ធានាខ្ចីប្រាក់បន្ថែមពីដើមចោទចំនួន**១៦០០០ ( មួយម៉ឺនប្រាំមួយពាន់**)ដុល្លារអាមេរិក

ហើយសហចុងចម្លើយសន្យាសងប្រាក់ទៅដើមចោទវិញ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ ។ ក្នុងកិច្ចសន្យាខាងលើឈ្មោះសហចុងចម្លើយឈ្មោះ[redacted] ដាលី សន្យាថា ក្នុងករណីសងទៅដើមចោទមិនទាន់ពេលវេលាតាមកិច្ចសន្យាទេ សហចុងចម្លើយឈ្មោះ [redacted] ដាលី ត្រូវបង់ប្រាក់ពិន័យ**ចំនួន១០០០ ( មួយពាន់** )ដុល្លាអាមេរិក បន្ថែមទៅឱ្យដើមចោទ ។

**៦-លើកទី៦ នៅចុងឆ្នាំ ឆ្នាំ២០១៩** សហចុងចម្លើយឈ្មោះ [redacted] ដាលី បានមកធ្វើកិច្ចសន្យាខ្ចីប្រាក់បន្ថែមពីដើមចោទ ដោយមិនបានដាក់ ធានាអ្វីទាំងអស់ចំនួន១៥០០( មួយពាន់ប្រាំរយ )ដុល្លាអាមេរិកដើមចោទយល់ព្រមឱ្យខ្ចីទៀត ហើយសហចុងចម្លើយឈ្មោះ[redacted] ដាលីថានឹងសងប្រាក់មកដើមចោទទាំងអស់ក្នុងពេលឆាប់ៗនេះ តែសហចុងចម្លើយឈ្មោះ [redacted]ដាលី មិនបានគោរពតាមកិច្ចសន្យានីមួយៗខាងលើនិងមិនបានសងប្រាក់មកដើមចោទទេថែមទាំងបានរត់គេចខ្លួនទៀត ។ នៅក្នុងកិច្ចសន្យាខ្ចីប្រាក់ទាំង០៦លើកខាងលើ សហចុងចម្លើយឈ្មោះ [redacted] ដាលី ម្នាក់ឯងជាអ្នកយកប្រាក់ពីដើមចោទផ្ទាល់ដៃ រីឯចំពោះសហចុងចម្លើយឈ្មោះ [redacted] ដាលី និងឈ្មោះ[redacted] ចន្ថា គ្រាន់តែជានាំមកខ្ចីនិងជាអ្នកដឹងឮធ្វើជាសាក្សីនិងផ្តិតមេដៃលើកិច្ចសន្យាខ្ចីចងប្រាក់រវាងដើមចោទ និងសហចុងចម្លើយឈ្មោះ[redacted] ដាលី តែប៉ុណ្ណោះ ។ ចំពោះការទាមទាររបស់ដើមចោទខាងលើ គឺសំអាងទៅលើកិច្ចសន្យាចុះថ្ងៃទី០១ខែឧសភាឆ្នាំ២០១៨ របស់សហចុងចម្លើយឈ្មោះ [redacted] ដាលី ជាមួយដើមចោទឈ្មោះ [redacted] គីមឡៃ ពិតប្រាកដមែន។ ដូច្នេះតុលាការសម្រេចឱ្យសហចុងចម្លើយឈ្មោះ [redacted] ដាលី តែម្នាក់សងប្រាក់ដើមចំនួន៧៤០០០ (ប្រាំពីរម៉ឺនបួនពាន់)ដុល្លាអាមេរិកនិងការប្រាក់ចំនួន៥ភាគរយ( ប្រាំភាគរយ )ក្នុង០១ឆ្នាំដោយចាប់គិតពីថ្ងៃចុះកិច្ចសន្យានៅថ្ងៃទី០១ខែឧសភាឆ្នាំ២០១៨រហូត ដល់ថ្ងៃសងប្រាក់ដើមអស់ទៅឱ្យដើមចោទឈ្មោះ[redacted] គីមឡៃទៅឱ្យដើមចោទតាមការទាមទាររបស់ដើមចោទខាងលើ តែចំពោះសហចុងចម្លើយឈ្មោះ [redacted]ដាលី និងឈ្មោះ[redacted] ចន្ថា វិញ តុលាការសម្រេចធ្វើការច្រានចោលការទាមទាររបស់ដើមចោទ ។

-ចំពោះចំណុចការទាមទាររបស់ដើមចោទត្រង់ចំណុចប្រាក់ពិន័យចំនួន០៦លើកតាមកិច្ចសន្យាចុះថ្ងៃទី០១ ខែឧសភាឆ្នាំ២០១៨សរុបចំនួន០៦ដងមានប្រាក់ពិន័យសរុបចំនួន៥៥០០( ប្រាំពាន់ប្រាំរយ )ដុល្លាអាមេរិក ដែលដើមចោទទាមទារឱ្យសហចុងចម្លើយសងនោះ តុលាការធ្វើការច្រានចោល ដោយសំអាងថា ពុំមានច្បាប់ចែង ។

**-ការទាមទាររបស់ដើមចោទត្រង់ចំណុចទី២**

-ដើមចោទបានទាមទារឱ្យសហចុងចម្លើយឈ្មោះ [redacted] ដាលី.ឈ្មោះ[redacted] ចន្ថា និងឈ្មោះ[redacted] ដាលី សងជម្ងឺចិត្តចំនួន២០០០០ (ពីរម៉ឺន) ដោយសំអាងថាខ្លួនខាតបង់ពេលវេលា និងសោហ៊ុយឡើងចុះតុលាការដោយសារសហចុងចម្លើយជាអ្នកបង្កឡើងនិងសហចុងចម្លើយជាអ្នកបង្កើតកិច្ចសន្យាម្តងហើយម្តងទៀតរហូតដល់រយៈពេល០៦ដងដែលធ្វើឱ្យដើមចោទមានជំនឿ ការលើកឡើងនិងការទាមទាររបស់ដើមចោទបែបនេះតុលាការជឿនិងសម្រេចឱ្យសហចុងចម្លើយឈ្មោះ[redacted] ដាលី ម្នាក់ឯងសងជំងឺចិត្តចំនួន២០០០០ (ពីរម៉ឺន)ដុល្លាអាមេរិកទៅឱ្យដើមចោទឈ្មោះ[redacted] គីមឡៃ តាមការទាមទាររបស់ដើមចោទ តែតុលាការសម្រេចធ្វើការច្រានចោលការទាមទាររបស់ដើមចោទឱ្យសហចុងចម្លើយឈ្មោះ[redacted] ដាលី និងឈ្មោះ[redacted] ចន្ថា សងជម្ងឺចិត្តទៅឱ្យខ្លួនដោយសំអាងថាសហចុងចម្លើយឈ្មោះ[redacted] ដាលី និងឈ្មោះ[redacted]ចន្ថា គ្រាន់តែផ្តិតមេដៃលើកិច្ចសន្យាខ្ចីចងការប្រាក់ក្នុងនាមជាសាក្សីប៉ុណ្ណោះ ។

Scanned with CamScanner

**-ការទាមទាររបស់ដើមចោទនូវចំណុចទី៣**

-ដើមចោទទាមទារឱ្យសហចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដីនិងប្រាក់ពន្ធផ្សេងៗទៀត ដោយបានសំអាងថារឿងទាំងអស់នេះសហចុងចម្លើយជាបង្កឡើងធ្វើឱ្យខ្លួនជាដើមចោទខាតបង់ពេលវេលា និងខាតបង់ប្រាក់ជាច្រើនទាំងសោហ៊ុយដាក់ពាក្យបណ្ដឹងទាំងសោហ៊ុយបង់ពន្ធនិងសោរហ៊ុយផ្សេងៗទៀត ។ តុលាការនិងសម្រេចតាមការទាមទាររបស់ដើមចោទ តែលើសហចុងចម្លើយឈ្មោះ [redacted] ដាលី តែម្នាក់ឯងប៉ុណ្ណោះ ចំពោះសហចុងចម្លើយឈ្មោះ[redacted] ដាលី និងចុងចម្លើយឈ្មោះ [redacted] ចន្ថា តុលាការធ្វើការច្រានការទាមទាររបស់ដើមចោទ ដោយហេតុថា សហចុងចម្លើយគ្រាន់តែជាសាក្សីដឹងឮថាសហចុងចម្លើយឈ្មោះ[redacted] ដាលី ជាអ្នកខ្ចីចងការប្រាក់ពីដើមចោទតែម្នាក់ឯង ។ ដោយយោងតាមមាត្រា៦៤នៃក្រមនីតិវិធីរដ្ឋប្បវេណីតុលាការសម្រេច ឱ្យសហចុងចម្លើយឈ្មោះ[redacted] ដាលី ជាអ្នកទទួលបន្ទុក ប្រាក់ប្រដាប់ក្ដី ។

**-ការទាមទាររបស់ដើមចោទនូវចំណុចទី៤**

-ដើមចោទទាមរទារឱ្យតុលាការប្រកាសជាបណ្ដោះអាសន្ននូវចំណុចទី១នៃការទាមទារប្រាក់ដើមចំនួន៧៤០០០(ប្រាំពីរម៉ឺនបួនពាន់) ដុល្លារអាមេរិក ដោយសំអាងថា ប្រសិនជារឿងនេះទុកឱ្យសហចុងចម្លើយបន្តប្ដឹងផ្ដល់ទៅតុលាការថ្នាក់លើបន្តទៀត នាំឱ្យខ្លួនជាដើមចោទខាតបង់ពេលវេលានិងខាតបង់ផលប្រយោជន៍របស់ដើមចោទជាច្រើន ។ដូច្នេះតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ ចោទតែលើសហចុងចម្លើយឈ្មោះ[redacted] ដាលី តែម្នាក់ឯងប៉ុណ្ណោះ ។ចំពោះសហចុងចម្លើយឈ្មោះ[redacted] ដាលី និងចុងចម្លើយឈ្មោះ[redacted] ចន្ថា តុលាការធ្វើការច្រានចោលការទាមទាររបស់ដើមចោទ ព្រោះសហចុងចម្លើយទាំងពីរនាក់គ្រាន់តែជាសាក្សីនិងផ្ដិតមេដៃលើកិច្ចសន្យាខ្ចីចងការប្រាក់ដឹងឮថាសហចុងចម្លើយឈ្មោះ[redacted] ដាលី ខ្ចីចងការប្រាក់ពីដើមចោទតែប៉ុណ្ណោះ ។

## សេចក្ដីសម្រេចបញ្ចប់

**១**-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ[redacted] ដាលី ភេទស្រីសងប្រាក់ដើមឱ្យទៅដើមចោទឈ្មោះ[redacted] គីមឡៃ ភេទស្រី**ចំនួន៧៤០០០ (ប្រាំពីរម៉ឺនបួនពាន់)ដុល្លារអាមេរិក ។**

**២**-ច្រានចោលការទាមទារប្រាក់ពិន័យចំនួន៥៥០០( ប្រាំពាន់ប្រាំរយ )ដុល្លារអាមេរិករបស់ដើមចោទទៅលើសហកូនបំណុលឈ្មោះ **ចាន់ ដាលី** ។

៣-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ដាលី សងការប្រាក់ **ចំនួន៥ភាគរយក្នុង០១ឆ្នាំ( ប្រាំភាគរយក្នុងមួយឆ្នាំ ) នៃប្រាក់ដើមចំនួន៧៤០០០( ប្រាំពីរម៉ឺនបួនពាន់ )ទៅឱ្យដើមចោទឈ្មោះ[redacted] គីមឡៃ** ដោយគិតចាប់ពីថ្ងៃ ទី០១ ខែឧសភា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងប្រាក់ទៅឱ្យដើមចោទគ្រប់ចំនួន។

Scanned with CamScanner

៤-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ[redacted] ដាលី សងជំងឺចិត្តចំនួន២០០០០(ពីរម៉ឺន)ដុល្លារអាមេរិកទៅឱ្យដើមចោទឈ្មោះ[redacted] គីមឡៃ

៥-ឱ្យសហចុងចម្លើយឈ្មោះ[redacted]ដាលី ជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដីនិងប្រាក់ពន្ធផ្សេងៗ ។

៦-ឱ្យប្រកាសអនុវត្តជាបណ្ដោះអាសន្នលើចំណុចទី១ នៃការទាមទារក្នុងសេចក្ដីសម្រេចខាងលើ ។

ថ្ងៃពុធ ០៥កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

សៀមរាប ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ។

ចៅក្រម

ហត្ថលេខានិងត្រា[redacted]

---

បានឃើញ

សៀមរាប ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២

ចៅក្រម

[redacted]

បានវាយចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម ។

ថ្ងៃពុធ០៥កើតខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

សៀមរាប ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ។

ក្រឡាបញ្ជី

[redacted]

Scanned with CamScanner